គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ខុមហ្វ្រែល COMFREL

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក **ធុន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារ៉ាយ៉េត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សឺន សែត**
Mr. SEN Set

ស.ប្រ.ក.៣/លេខ ២៨/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត បន្ទាយមានជ័យ

*ភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨០នាក់ មកពីស្រុកផ្សេងគ្នា និងក្រុងនៅក្នុងខេត្តបន្ទាយមានជ័យ ដែលក្នុងនោះមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ២៦% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌ សន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តបន្ទាយមានជ័យ ។

អភិបាលរងខេត្តបន្ទាយមានជ័យ លោក **វឿម សារិន** បានមានប្រសាសន៍ នៅក្នុងសិក្ខាសាលាថា លោកមានការគាំទ្រយ៉ាងខ្លាំងក្លាអោយមានការរៀបចំសិក្ខាសាលានេះឡើង ដែលសិក្ខាសាលានេះរកឃើញសេចក្តីត្រូវការភាពជាក់ស្តែងដែលប្រជាពលរដ្ឋបានលើកឡើង ។

អ្នកតំណាងរាស្ត្រ **ញឹក ប៊ុនឆៃ** មណ្ឌលបន្ទាយមានជ័យ និងសមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ ឯកឧត្តម **ជង់ ប្រស៊ើដ្ឋ** មកពីគណបក្សប្រជាជនកម្ពុជា ឯកឧត្តម **កែវ សម្ផស្ស** មកពីគណបក្សសមរង្ស៊ី ដែលបានទទួលលទ្ធផលនៃវិស័យអាទិភាពទាំង ១០ ហើយបានសន្យា និងឯកភាពទាំងស្រុងចំពោះអ្វីដែលប្រជាពលរដ្ឋលើកឡើងដែលសុទ្ធតែជាចំនុចសំខាន់ និងចាំបាច់ក្នុងការអភិវឌ្ឍន៏ខេត្ត ជាពិសេសនឹងលើកឡើងនៅពេលប្រជុំក្រុមប្រឹក្សាខេត្ត។ ដោយឡែកការងារមួយចំនួនដែលពាក់ព័ន្ធថ្នាក់ជាតិ ប្រគល់ជូនថ្នាក់ជាតិដោះស្រាយ ហើយបញ្ហាដែលទាក់ទងថ្នាក់ខេត្តនោះថ្នាក់ខេត្តនឹងដោះស្រាយ ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តបន្ទាយមានជ័យដូចខាងក្រោម:

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តបន្ទាយមានជ័យរួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្ត បន្ទាយមានជ័យ** |
|---|
| ១) សុំឱ្យមន្ទីរពេទ្យបង្អែកទូទាំងខេត្តបន្ទាយមានជ័យ ទទួលព្យាបាលអ្នកជំងឺក្រីក្រដោយមិនយកកំរៃ និងយកចិត្តទុកដាក់ដល់ អ្នកជំងឺ ព្រមទាំងសុំកាត់បន្ថយការបង់ថ្លៃសេវាព្យាបាលឱ្យបាន ៣៥% ចាប់ពីដើមឆ្នាំ២០១០ នេះតទៅ។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលជួយជំរុញដល់សភា ឱ្យអនុម័តច្បាប់ប្រឆាំងអំពើពុករលួយអោយបាននៅដើមឆ្នាំ២០១០ ។ |
| ៣) សុំឱ្យរាជរដ្ឋាភិបាល ជួយបង្កើនប្រាក់បៀវត្សរ៍ដល់គ្រូឱ្យបាន ៤០% [ ក្នុងមួយឆ្នាំរហូតប្រាក់ខែកើនសមល្មមសំរាប់ជីវភាព ] ព្រមទាំងផ្តល់កន្លែងស្នាក់នៅដល់គ្រូ មកពីឆ្ងាយ យ៉ាងតិច មួយសាលាឱ្យបាន ២បន្ទប់ ឱ្យបានចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ៤) សុំឱ្យរដ្ឋាភិបាលជួយទប់ស្កាត់ការកាប់ព្រៃឈើនៅតំបន់ស្វាយចេក និងតំបន់ភ្នំដងរែក នៅស្រុកថ្មពួកខេត្ត បន្ទាយមានជ័យឱ្យបាន ១00% ដែលចាប់អនុវត្តពីខែ ធ្នូ ឆ្នាំ ២០០៩ តទៅ។ |
| ៥) សុំរាជរដ្ឋាភិបាលជួយបញ្ចុះតម្លៃអគ្គិសនី ឱ្យមកត្រឹមតែ ៦00រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ទូទាំងខេត្តបន្ទាយមានជ័យ ចាប់ពី ខែមករា ឆ្នាំ២០១០ នេះតទៅ។ |
| ៦) សុំរាជរដ្ឋាភិបាលជួយឱ្យមានរោងចក្រកាត់ដេរ នៅក្នុងក្រុងប៉ោយប៉ែត ( នៅភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ ប៉ោយប៉ែត ក្រុង ប៉ោយប៉ែត) អាចប្រើប្រាស់កម្លាំង កម្មករប្រហែល ១000នាក់ ចាប់ដំណើរការពីឆ្នាំ២០១០ នេះតទៅ។ |
| ៧) សុំរាជរដ្ឋាភិបាលជួយជួសជុលផ្លូវលំ ចំនួន ៦ខ្សែ មានដូចជា ខ្សែទី១ ពីភូមិព្រៃមាន់ ទៅទីរួមស្រុកភ្នំស្រុក មានប្រវែង ១៧គម និងទទឹង ៧ម។ ខ្សែទី២ ពីឃុំរហាត់ទឹក ទៅឃុំសឿ ក្នុងស្រុកមង្គលបុរី ដែលមានប្រវែង ១០គម ទទឹង ៥ម ។ ខ្សែទី៣ ពីទីរួមស្រុកមង្គលបុរី ទៅឃុំស្រះរាំង ប្រហែល ១៥គម និងទទឹង ៧ម។ ខ្សែទី៤ ពីទីរួមស្រុកស្វាយចេក ទៅឃុំតាផូ មានប្រវែង ១០គម និង ទទឹង ៦ម។ ខ្សែទី៥ ភូមិចក សង្កាត់ព្រះពន្លា មានប្រវែង ៣000ម និង ទទឹង ៦ម។ ខ្សែទី៦ ចូល ក្រុមទី៥ ភូមិ១ សង្កាត់ព្រះពន្លា ប្រវែង ១00ម ទទឹង ២ម ហើយផ្លូវទាំងអស់នេះ សុំឱ្យចាប់កសាងនៅក្នុងដើមឆ្នាំ២០១០ បញ្ចប់នៅក្នុងចុងឆ្នាំ២០១០។ |
| ៨) សំណូមពរដល់ក្រសួងសុខាភិបាលចាត់វិធានការជួយពង្រឹងដល់បុគ្គលិកសុខាភិបាលឱ្យគោរពតួនាទី និងឱ្យមានក្រមសីលធមិដល់ អ្នកជំងឺ និងសុំជួយបង្កើនប្រាក់ខែបុគ្គលិកពេទ្យឱ្យបាន ៤០% [ ក្នុងមួយឆ្នាំរហូតប្រាក់ខែកើនសមល្មមសំរាប់ជីវភាព ] នៅក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីដើម ឆ្នាំ២០១០ នេះតទៅ។ |
| ៩) សុំឱ្យរដ្ឋាភិបាលជួយរកទីផ្សារ សំរាប់លក់កសិផល នៅទូទាំង ខេត្តបន្ទាយមានជ័យ ឱ្យមានតម្លៃប្រហាក់ប្រហែលប្រទេស ជិតខាង ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ១០) សុំឱ្យរាជរដ្ឋាភិបាលជួយលើកស្ទួយតួនាទីរបស់ស្ត្រីដែលមានសមត្ថភាពក្នុងការដឹកនាំ នៅគ្រប់លំដាប់ថ្នាក់ ក្នុងខេត្តបន្ទាយមានជ័យ ឱ្យបាន ៥0% ចាប់ ពីឆ្នាំ២០១០នេះតទៅ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), អង្គការអភិវឌ្ឍន៍សុខភាពសត្វជនបទ (RADHO), សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) (CHHRA) ដែលក្នុងនោះ មានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកមង្គលបុរី ស្រុកព្រះនេត្រព្រះ ស្រុកអូរជ្រៅ ស្រុកស្វាយចេក ស្រុកម៉ាឡៃ និងក្រុងសិរីសោភ័ណ្ឌនៅក្នុង ខេត្តបន្ទាយមានជ័យ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨
២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន
៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:*

- លោក **កុយ ចំនួនវិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦